# ម៉ូលឌុល ១ : សេចក្តីណែនាំអំពីកម្មសិទ្ធិបញ្ញា

## តើអ្វីទៅជាកម្មសិទ្ធិបញ្ញា?

ជាទូទៅ លោក លោកស្រីប្រហែលជាបានដឹងចម្លើយនៃសំនួរនេះហើយ។ យើងដឹងហើយថាអ្នកបង្កើតម៉ាស៊ីន អ្នកនិពន្ធសៀវភៅ ឬក៏អ្នកនិពន្ធទំនុកភ្លេង តែងតែជាម្ចាស់នៃស្នាដៃរបស់ខ្លួន។ កើតចេញពីកម្មសិទ្ធិនេះហើយដែលធ្វើអោយមជ្ឈដ្ឋានខាងក្រៅ មិនអាចថតចំលង ឬក៏ទិញការថតចំលងដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិបានទេ។ ជាធម្មតា មានគំរូដើមនៃឧស្សាហកម្មគឿងសង្ហារឹម ឬក្រដាសបិទជញ្ជាំងនិងរបស់ផ្សេងទៀត ដែលជាទូទៅជាកម្មសិទ្ធិ របស់បុគ្គលណាម្នាក់ឬអង្គការណាមួយ។

រាល់ពេលដែលយើងបានទិញទំនិញដែលបានទទួលកិច្ចការពារក៏មានន័យថា យើងបានផ្តល់នូវតំលៃនៃការចំណាយពេលវេលា លុយកាក់ ការខំប្រឹង ការពិចារណាក្នុងការបង្កើតទំនិញនេះទៅអោយម្ចាស់ដើមវិញ។កិច្ចការនេះមានជាឆ្នាំមកហើយក្នុងការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម មានដូចជាការរីកលូតលាស់នៃឧស្សាហកម្មត្វូរ្យតន្ត្រីនៅលើពិភពលោក និងការលើកទឹកចិត្តដល់អ្នកមានទេពកោសល្យថ្មីៗអោយបង្កើតនូវគំនិតនិងអត្តបទខ្លួនឯងអោយកាន់តែច្រើន។

©WIPO/OMPI

តារាងខាងក្រោមជាការបង្ហាញនូវទំនិញឬសេវាកម្មមួយចំនួនដែលមានសិទ្ធិ ទទួលបានកិច្ចការពារពីកម្មសិទ្ធិបញ្ញាក្រោមច្បាប់កម្មសិទ្ធិបញ្ញាជាតិ និង/ឬសន្ធិសញ្ញាអន្តរជាតិផ្សេងៗ :

| ថាសមូលតូច(Discs) | ការរចនារូបរាង | ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញសម្រាប់ប្រភេទផលិតផលមួយចំនួន |
|---|---|---|
| ការសំដែង | រូបភាព | ឈ្មោះរបស់ក្រុមហ៊ុន |
| ការផ្សាយតាមវិទ្យុ ឬទូរទស្សន៍ | និមិត្តសញ្ញ | ចង្វាក់ឧស្សាហកម្ម |
| វីដេអូ | ពាណិជ្ជសញ្ញា (និក្ខិត្តសញ្ញា) | រូបមន្តគីមី |
| ល្បែងក្នុងកុំព្យូទ័រ (game) | សៀគ្វីបង្រួម | វត្ថុធាតុ/សារធាតុ(ដើម) |
| កម្មវិធីកុំព្យូទ័រ | ការច្នៃប្រឌិតថ្មី | ទឹកអប់ |

©WIPO/OMPI

ការផ្ដើមជាមួយនិយមន័យផ្លូវការរបស់កម្មសិទ្ធិបញ្ញាគឺដើម្បីជាមូលដ្ឋានសម្រាប់ការពន្យល់លើកក្រោយនៃប្រភេទកម្មសិទ្ធិបញ្ញាផ្សេងៗទៀត និងសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ។ ឧទាហរណ៍ល្អបំផុតដើម្បីពិចារណាគឺពាក្យទ្រព្យសម្បត្តិ។

លក្ខណៈទូទៅនៃទ្រព្យសម្បត្តិភាគច្រើន គឺកម្មសិទ្ធិករនៃទ្រព្យសម្បត្តិ មានសេរីភាពពេញលេញក្នុងប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួន លើកលែងតែការប្រើប្រាស់នោះ ខុសច្បាប់ ហើយ អាចរារាំងបុគ្គលដទៃមិនឱ្យប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួន។

ឥឡូវនិយាយអំពីពាក្យថា" កម្មសិទ្ធិបញ្ញា " គឺត្រូវបានផ្ដល់សិទ្ធិតាមប្រភេទនៃទ្រព្យសម្បត្តិ ដែលហៅថា(កម្មសិទ្ធិ)ដែលចេញពីការបង្កើតនៃគំនិតបញ្ញារបស់មនុស្ស។ពាក្យកម្មសិទ្ធិបញ្ញានៅក្នុង"អនុសញ្ញាបង្កើតអង្គការកម្មសិទ្ធិបញ្ញាពិភពលោក "ឬ"អង្គការកម្មសិទ្ធិបញ្ញាពិភពលោក(WIPO)"មិនមាននិយមន័យផ្លូវការជាងនេះនោះទេ។

រដ្ឋនានាដែលពង្រាងអនុសញ្ញាបានជ្រើសយកនូវបញ្ជីរួមមួយទាក់ទងទៅនឹងសិទ្ធិដូចខាងក្រោម

" ស្នាដៃអក្សរសាស្ត្រ សិល្បៈ និង វិទ្យាសាស្ត្រ ការសំដែងសិល្បះហ្វូណូក្រាមនិងការផ្សាយតាមវិទ្យុ ឬទូរទស្សន៍ គ្រប់ការច្នៃប្រឌិតគ្រប់វិស័យនៃការខំប្រឹងរបស់មនុស្ស របកគំហើញនៃវិទ្យាសាស្ត្រ គំរូឧស្សាហកម្ម ពាណិជ្ជសញ្ញា សេវាសញ្ញានិងពាណិជ្ជនាមហើយនិងសញ្ញាសម្គាល់នានា(designations) កិច្ចការពារប្រឆាំងនឹងការប្រកួតប្រជែងមិនស្មោះត្រង់និងគ្រប់សិទ្ធិទាំងអស់ ដែលកើតចេញពីកម្មភាពបញ្ញាក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬ វិស័យ សិល្បៈ"។(កិច្ចព្រមព្រៀងបង្កើតអង្គការកម្មសិទ្ធិបញ្ញាពិភពលោកចូលជាធរមាននៅស្តុកខុល(STOCKHOLM) ថ្ងៃ១៤ កក្កដា ១៩៦៧ មាត្រា២ viii) ។

©WIPO/OMPI

សម្រាប់មូលហេតុរដ្ឋបាល និងប្រវត្តិសាស្ត្រកម្មសិទ្ធិបញ្ញាជាទូទៅទាក់ទង់នឹងប្រភេទស្នាដៃសំខាន់ៗដូចខាងក្រោម :

1. ស្នាដៃអក្សរសាស្ត្រ,សិល្បៈនិងវិទ្យាសាស្ត្រ ឧ សៀវភៅផ្សេងៗ។កិច្ចការពារកម្មសិទ្ធិ (ទ្រព្យសម្បត្តិ)នេះគឺគ្រប់គ្រងដោយច្បាប់* **សិទ្ធិអ្នកនិពន្ធ(copyright)**។
2. ការសំដែង,ការផ្សាយតាមវិទ្យុឬទូរទស្សន៍ ឧ.ការប្រគុំតន្ត្រី។ កិច្ចការពារកម្មសិទ្ធិ (ទ្រព្យសម្បត្តិ)នេះគឺគ្រប់គ្រងដោយ**សិទ្ធិប្រហាក់ប្រហែល** ក្នុងច្បាប់ **សិទ្ធិអ្នកនិពន្ធ (Copy Rights)**។
3. តក្កកម្ម(ការច្នៃប្រឌិតថ្មី) ឧ. ទំរង់ថ្មីរបស់ម៉ាស៊ីនយន្តហោះប្រតិកម្ម។ កិច្ចការពារកម្មសិទ្ធិ (ទ្រព្យសម្បត្តិ)នេះគឺផ្អែកលើច្បាប់ប្រកាសនីយបត្រតក្កកម្ម ( Patents )។
4. គំនូឧស្សាហកម្ម ឧ.រូបរាងដបភេសជ្ជះ។ **គំរូឧស្សាហកម្ម**ត្រូវបានការពារដោយច្បាប់ពិសេសរបស់គំនូរឧស្សាហកម្ម ឬច្បាប់កម្មសិទ្ធិឧស្សាហកម្មឬច្បាប់សិទ្ធិអ្នកនិពន្ធ(Copy Right)ដែរ។
5. ពាណិជ្ជសញ្ញា សេវាសញ្ញា និង ពាណិជ្ជនាម ព្រមទាំងសញ្ញាសម្គាល់នានា ឧ. និមិត្តសញ្ញាឬឈ្មោះទំនិញដែលជាម៉ាកសម្គាល់ភូមិសាស្ត្រពិសេស ដូចជាស្រាសាំស្បាញ(champagne)។ជាទូទៅកិច្ចការពារនេះ អាចមាននៅក្រោមច្បាប់ផ្សេងៗ។ វគ្គសិក្សានេះ គ្រប់ដណ្តប់លើ**ច្បាប់ស្តីពីម៉ាក**។
6. កិច្ចការពារប្រឆាំងនឹហាការប្រកួតប្រជែងមិនស្មោះត្រង់ ឧ. ការធ្វើអោយយល់ខុសប្រឆាំងនឹងគូប្រកួតប្រជែង ឬធ្វើត្រាប់តាមគូប្រកួតប្រជែងដោយមានបំណងឆបោកអតិថិជន។នេះជាប្រធានបទដែលមានក្នុងម៉ូឌុលជាច្រើនក្នុងវគ្គសិក្សានេះ។ ជាក់ស្តែង វាជាប្រធានបទនៃម៉ូឌុលផ្សេង។

---

*ពាក្យ" ច្បាប់"រួមបញ្ចូលទាំងច្បាប់ជាតិ និង កិច្ចព្រមព្រៀងអន្តរជាតិ: សិទ្ធិសញ្ញា, អនុសញ្ញា និង លិខិតុបករណ៍អន្តររដ្ឋាភិបាលប្រហាក់ប្រហែល។ សិទ្ធិសញ្ញារដ្ឋាភិបាលខអាចទទួលប្រព្រឹត្តិកម្មផ្សេងៗគ្នាក្នុងដ្ឋាភិបាលប្រទេសផ្សេង។

©WIPO/OMPI

## សំណួរវាយតម្លៃខ្លួនឯង( SAQ )

SAQ១: សម្រាប់ឧទាហរណ៍កម្មសិទ្ធិបញ្ញានីមួយៗខាងក្រោមស្ថិតនៅក្នុងចង្កោមច្បាប់កម្មសិទ្ធិបញ្ញាដែលសក្តិសមសម្រាប់ទទួលបានកិច្ចការពារ:

១. ក្រុមហ៊ុនមួយមានបំណងថាមិនអោយនរណាប្រើប្រាស់និមិត្តសញ្ញារបស់ខ្លួន ។

២. អ្នកចំរៀងម្នាក់មានបំណងផ្ទេរសិទ្ធិអោយផលិតឡើងវិញនូវវីដេអូរបស់នាងក្នុងការសំដែងពេលប្រគុំតន្រ្តីរបស់នាង ។

៣. មានរូបមន្តថ្មីមួយដើម្បីផលិតទឹកដោះគោ ដែលគ្មានសារធាតុធ្វើអោយធាត់ចេញពីប្រូម៉ា ដែលធ្វើពីទឹកដោះគោនេះ។

៤. ក្រុមហ៊ុនមួយបានសំរេចចិត្តវិនិយោកលើសំបកវិចខ្ចប់ ដែលមានលក្ខណ:ញែកដាច់ហើយពួកគាត់មានបំណងប្រើផ្តាច់មុខ។

៥.ក្រុមហ៊ុនមួយសំរេចប្រើនិមិត្តសញ្ញាដែលមានរូបរាងដូចនឹងនិមិត្តសញ្ញារបស់ដៃគូរប្រគួតប្រជែង ប៉ុន្តែមានពណ៌ខុសគ្នា ។

សរសេរចម្លើយលោក លោកស្រីខាងក្រោម:

| |
|---|
| |

ចុចទីនេះសម្រាប់ចម្លើយ:

©WIPO/OMPI

**ចម្លើយ SAQ 1**

១. ពាណិជ្ជសញ្ញា

២. សិទ្ធិប្របហាក់ប្របហែល

៣. ប្រកាសនីយបត្រតក្កកម្ម

៤. គំរូឧស្សាហកម្ម

៥. ការប្រកួតប្រជែងមិនស្មោះត្រង់

©WIPO/OMPI

សូមកុំបារម្ភប្រសិនបើលោក លោកស្រីមិនអាចបំពេញត្រឹមត្រូវទាំងអស់។ វគ្គសិក្សាបន្ទាប់ យើងនឹងសិក្សាប្រភេទនីមួយៗនៃកម្មសិទ្ធិបញ្ញាទាំងនេះនិងពន្យល់គោលការណ៍នៃប្រភេទកម្មសិទ្ធិបញ្ញាទាំងនេះ ។

គោលការណ៍ជារួមពីរនៃកម្មសិទ្ធិបញ្ញាទាំងនេះ

- អ្នកបង្កើតកម្មសិទ្ធិបញ្ញានឹងទទួលបានសិទ្ធិដែលជាលទ្ធផលនៃការងាររបស់ខ្លួន
- គ្រប់ស្នាដៃ(សិទ្ធិ)អាចត្រូវបានផ្ទេរ ឬ អាចត្រូវបានចេញអាជ្ញាបណ្ណ័ឲ្យទៅអ្នកដទៃបានផងដែរ ។

©WIPO/OMPI

## ហេតុអ្វីចាំបាច់មានកម្មសិទ្ធិបញ្ញា ?

មូលហេតុដំបូងគឺថាវាសមស្របដែលបុគ្គលណាម្នាក់ខិតខំប្រឹងប្រែងទាំងកំលាំង និងចិត្តក្នុងការបង្កើតផ្នែកបញ្ញា ទទួលបានផលប្រយោជន៍ពីការខិតខំប្រឹងប្រែងនេះ។ មូលហេតុបន្ទាប់ គឺថាតាមរយៈការផ្តល់កិច្ចការពារកម្មសិទ្ធិបញ្ញាជម្រុញឱ្យមានការកើនឡើងនូវការខិតខំប្រឹងប្រែងក្នុងការបង្កើតថ្មី ហើយអាចធ្វើអោយឧស្សាហកម្មលើផលិតផលទាំងនេះ មានរីកលូតលាស់ ដោយសារគេគិតថា ការងារទាំងនេះ ផ្តល់ផលប្រយោជន៍ហិរញ្ញវត្ថុដល់ខ្លួន។

ឧទាហរណ៍នៃចំណុចក្រោយនេះគឺជាករណីផ្តល់ដោយឧស្សាហកម្មឱសថពិភពលោក។ ការវិនិយោគជាច្រើនឆ្នាំនិងការចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍ(R&D) (ពេលវេលាក្នុងទីពិសោធនក្នុងការបង្កើតថ្មី ការធ្វើតេស្ត នីតិវិធីនៃការអនុញ្ញាតពីភ្នាក់ងារឬរដ្ឋាភិបាល) អស់រាប់រយលានដោនស្ទើរលីង ( ឬលុយយេនលុយរ៉េង់ លុយlira និងដុល្លា) ត្រូវការចាំបាច់មុនពេលឱសថថ្មីៗឈានទៅដល់ទីផ្សារ។ ភាពគ្មានសិទ្ធិកម្មសិទ្ធិបញ្ញាដើម្បីទប់ស្កាត់គូប្រកួតប្រជែងមិនឱ្យផលិតឱសថដែលបានបង្កើតនោះ ក្រុមហ៊ុនឱសថដែលបង្កើតឱសថនោះ ហាក់គ្មានការលើកទឹកចិត្តក្នុងការចំណាយទាំងពេលវេលានិងការខិតខំដូចខាងលើដើម្បីអភិវឌ្ឍន៍ឱសថរបស់ខ្លួនឡើយ។

ភាពគ្មានកិច្ចការពាររបស់ប្រកាសនីយបត្រតក្កកម្ម(Paten) ក្រុមហ៊ុនមួយនឹងប្រឈរមុខនឹងការបាត់បង់ទីផ្សារ ដែលបណ្តាលមកពីការ"ជិះសេះលែងដៃ" របស់គូប្រកួតប្រជែង។ភាពគ្មានកិច្ចការពារ ម៉ាកក្រុមហ៊ុនខាងលើនេះមិនអាចពង្រឹងភាពស្មោះត្រង់ចំពោះម៉ាក"(brandloyalty")ដែលមានរយៈពេលលើសពីរយៈពេលការពារដោយប្រកាសនីយបត្រតក្កកម្ម។

ភាពគ្មានកិច្ចការពារផ្តល់ដោយច្បាប់កម្មសិទ្ធិបញ្ញា និងសន្ធិសញ្ញាផ្សេងៗទេ ក្រុមហ៊ុនឱសថទាំងនេះគ្មានការប្តេជ្ញាចិត្តក្នុងការខិតខំប្រឹងប្រែង ដើម្បីពិសោធន៍ស្វែងរកផលិតផលជំនួយសុខភាពថ្មទៀតឡើយ។ ដូចជាអ្នកឃើញឧទាហរណ៍យ៉ាងខ្លីខាងលើថា បើគ្មានកិច្ចការពារដូចខាងលើ ពិភពលោកប្រហែលជាមិនមានសុខភាពល្អដូចបច្ចុប្បន្ននេះនោះទេ។

សិទ្ធិកម្មសិទ្ធិបញ្ញា ក៏ពង្រីកកិច្ចការពារផងដែរដល់កម្មវត្ថុផ្សេងទៀតដូចជាការសម្តែងវប្បធម៌ដែលមិនបានកត់ត្រាទុកនិងថតចម្លងទុករបស់ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ជាទូទៅគេស្គាល់ថាជាប្រពៃណីឬទំនៀមទំលាប់របស់ប្រទេសណាមួយ(folklore) ។ជាមួយ

©WIPO/OMPI

កិច្ចការការពារកម្មវត្ថុទាំងនេះ ពួកគេអាចធ្វើអាជីវកម្មដើម្បីទាញយកផលចំណេញឱ្យប្រទេសនិង ប្រភពដើមនៃវប្បធម៌ទាំងនោះ។

©WIPO/OMPI

ហេតុផលសម្រាប់ប្រទេសមួយចំនួនដែលអនុម័តច្បាប់ជាតិនិងចូលរួមចហត្ថលេខាលើសិទ្ធិសញ្ញាតំបន់ឬ អន្តរជាតិ ឬ ទាំងតំបន់និងអន្តរជាតិដែលគ្រប់គ្រងលើកម្មសិទ្ធិបញ្ញារួមមាន:

- ផ្តល់ការលើកទឹកចិត្តលើការខិតខំប្រឹងបង្កើតគំនិតផ្សេងៗដោយទទួលបាននូវកិច្ចការពារ
- ផ្តល់គ្រប់អ្នកបង្កើតឬអ្នកច្នៃប្រឌិតនូវការទទួលស្គាល់ជាផ្លូវការ។
- បង្កើតកន្លែងទុកដាក់ពត៌មាន(ឯកសារ)សំខាន់ៗ។
- សំរួលដល់ការកើតឡើងទាំងឧស្សាហាកម្មក្នុងស្រុក ឬ វប្បធម៌ និងពាណិជ្ជកម្មអន្តរជាតិ ហើយតាមរយៈសិទ្ធិសញ្ញាទាំងនេះនឹងផ្តល់នូវកិច្ចការពារដែលមានច្រើនផ្នែក។

នៅផ្នែកបន្ទាប់នៃវគ្គសិក្សានេះ
យើងគួរតែប្រលងតាមផ្នែកនីមួយៗនៃកម្មសិទ្ធិបញ្ញាដែលបានលើកឡើងខាងលើ។

©WIPO/OMPI